# សលាកប័ត្រព័ត៌មាន៖ ការបណ្តេញចេញដោយបង្ខំនៅកម្ពុជា

**ទិដ្ឋភាពរួម៖** សលាកប័ត្រព័ត៌មាននេះត្រូវបានចងក្រងឡើង ដើម្បីបំពេញបន្ថែមទៅលើសលាកប័ត្រព័ត៌មានមុនដែលមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានចេញផ្សាយ ក្នុងឆ្នាំ២០២០ និង២០២១ និងភាគច្រើនផ្តោតសំខាន់ទៅលើការបណ្តេញចេញដោយបង្ខំនៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីការដកការរឹតបន្តឹងអំឡុងពេលជំងឺកូវីដ-១៩ នៅចុងឆ្នាំ២០២១។ បើទោះជាមានការចេញប័ណ្ណកម្មសិទ្ធដីធ្លីជិត ៧លានប័ណ្ណ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក្តី ការបណ្តេញចេញដោយបង្ខំនៅតែបន្តធ្វើឡើងដោយមិនគោរពសិទ្ធិមនុស្សរបស់ពលរដ្ឋដែលត្រូវបានគេបណ្តេញចេញនោះឡើយ។ សលាកប័ត្រព័ត៌មាននេះរំលឹកឡើងវិញអំពីកាតព្វកិច្ចសិទ្ធិមនុស្សដែលទាមទារឱ្យរដ្ឋ និងធុរកិច្ច ត្រូវការពារប្រជាពលរដ្ឋពីការបណ្តេញចេញដោយបង្ខំ និងផ្តល់អនុសាសន៍ជាក់លាក់ដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីដោះស្រាយបញ្ហានេះ និងការពារសិទ្ធិលំនៅឋាន និងដីធ្លីរបស់ប្រជាពលរដ្ឋរបស់ខ្លួន។

## ១. សេចក្តីផ្តើម

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលបានផ្តល់ដីយ៉ាងច្រើនសន្ធឹកសន្ធាប់សម្រាប់ការអភិវឌ្ឍ និងអាជីវកម្មដល់ក្រុមហ៊ុនក្នុងស្រុក និងអន្តរជាតិ។ ដោយសារប្រព័ន្ធចុះបញ្ជីដីធ្លីមិនរឹងមាំរបស់ប្រទេសអសន្តិសុខនៃសិទ្ធិកាន់កាប់ដីធ្លីជាផ្លូវការ និងនីតិរដ្ឋទន់ខ្សោយ បាននាំឱ្យមានជម្លោះដីធ្លីមានការកើនឡើងគួរឱ្យព្រួយបារម្ភ។ ខណៈដែលមិនមានទិន្នន័យជាផ្លូវការដែលអាចបញ្ជាក់បានពីការបណ្តេញចេញដោយបង្ខំ មានការប៉ាន់ប្រមាណថា មានប្រជាជនកម្ពុជាប្រមាណ ៤០០.០០០នាក់ ត្រូវបានបណ្តេញចេញដោយបង្ខំនៅចន្លោះឆ្នាំ ២០០៣ និង ២០១២[1] ដែលបច្ចុប្បន្នចំនួននេះអាចមានការកើនឡើង។ យោងតាមរបាយការណ៍របស់អង្គការសមាគមជាងត្នោត ឆ្នាំ២០២០ បានបង្ហាញថា គ្រាន់តែនៅក្នុងរាជធានីភ្នំពេញមួយប៉ុណ្ណោះ មានប្រជាពលរដ្ឋជិត ១០.០០០ គ្រួសារ (ប្រមាណជា ៤០.០០០នាក់) ត្រូវបានបណ្តេញចេញដោយពុំបានអនុវត្តតាមនីតិវិធីត្រឹមត្រូវតាំងពីអំឡុងទសវត្សរ៍ឆ្នាំ ១៩៨០។[2] ក្នុងសលាកប័ត្រព័ត៌មានមុនៗដែលចេញផ្សាយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») ក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១ បានបង្ហាញថា ការបណ្តេញចេញដោយបង្ខំ បាន

[1] ហ្វែន គ្រិនវូឌ «ការបណ្តេញចេញនៅកម្ពុជានៅតែបន្តដោយពុំមានការត្រួតពិនិត្យ» (គ្លូបិល ប៉ុស្ត៍ ថ្ងៃទី២២ ខែមករា ឆ្នាំ២០១២)
[2] អង្គការសមាគមជាងត្នោត «ការបណ្តេញចេញ និងការតាំងទីលំនៅថ្មី» (ខែមិថុនា ឆ្នាំ២០២០)

បន្តកើតមានឡើងក្នុងអំឡុងពេលជំងឺរាតត្បាតកូវីដ-១៩[3] ទោះជាអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិទទួលបានលំនៅឋានសមរម្យ បានអំពាវនាវឱ្យមានការផ្អាកជាសកលលើការបណ្តេញចេញក្នុងអំឡុងពេលនោះក៏ដោយ។[4]

ការបណ្តេញចេញដោយបង្ខំ គឺជាការរំលោភបំពានលើសិទ្ធិដីធ្លីដែលរីករាលដាលបំផុត ដោយសារការណ៍នេះជារឿយៗធ្វើឱ្យមានប្រជាពលរដ្ឋគ្មានផ្ទះសម្បែង ឬមិនអាចរកប្រាក់ចញ្ចឹមជីវិត ។ ការបណ្តេញចេញដោយបង្ខំបានបង្កើនវិសមភាពដែលមានស្រាប់ហើយនោះ រិតតែប៉ះពាល់ដល់សហគមន៍ក្រីក្រ និងសហគមន៍ងាយរងគ្រោះ ដោយរុញច្រានសហគមន៍ទាំងនោះឱ្យកាន់តែក្រីក្រទៅ។ ម.ស.ម.ក បានចងក្រងឯកសារករណីស្តីពីការបណ្តេញចេញដោយបង្ខំបន្ថែមទៀត ចាប់តាំងពីរាជរដ្ឋាភិបាលបានដកការរឹតបន្តឹងក្នុងអំឡុងពេលជំងឺកូវីដ-១៩ នៅចុងឆ្នាំ ២០២១។ នេះជាការព្រួយបារម្ភដ៏ពិសេសមួយ ដោយសារតែជាប្រពៃណីទៅហើយ ដែលគ្រួសារងាយរងគ្រោះ និងក្រីក្រ គឺជាជនរងគ្រោះដោយសារការបណ្តេញចេញដោយបង្ខំ បានបង្កើតឡើងនូវសម្ពាធអតិផរណាដែលកើនឡើងនៅឆ្នាំ ២០២២។[5] សលាកប័ត្រព័ត៌មាននេះរំលឹកឡើងវិញអំពីកាតព្វកិច្ចសិទ្ធិមនុស្សដែលទាមទារឱ្យរដ្ឋ និងធុរកិច្ច ត្រូវការពារប្រជាពលរដ្ឋ និងសហគមន៍ពីការបណ្តេញចេញដោយបង្ខំនៅក្នុងប្រទេសកម្ពុជា និងផ្តល់អនុសាសន៍ជាក់លាក់ដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីលើកកម្ពស់ការគោរពសិទ្ធិដីធ្លី និងលំនៅឋាន ព្រមទាំងទប់ស្កាត់ការបណ្តេញចេញដោយបង្ខំនៅទូទាំងប្រទេស។

## ក. និយមន័យ

> **តើអ្វីទៅជាការបណ្តេញចេញដោយបង្ខំ ?**
>
> ការបណ្តេញចេញដោយបង្ខំគឺជា «**ការជម្លៀសបុគ្គល គ្រួសារ និង/ឬសហគមន៍ជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ចេញពីផ្ទះ និង/ឬដីធ្លីរបស់ពួកគេដែលកំពុងកាន់កាប់ ដែលផ្ទុយពីឆន្ទៈរបស់ពួកគាត់** ដោយគ្មានការ**ផ្តល់ និងការទទួលបាននូវទម្រង់សមស្របនៃការការពារស្របច្បាប់ឬទម្រង់ការពារផ្សេងទៀត**»។
>
> គណៈកម្មាធិការ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (មតិទូទៅលេខ៧ អ៊ី/១៩៩៨/២២ ១៩៩៧)

**ការបណ្តេញចេញដោយបង្ខំ គឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្ស** ជាពិសេសរំលោភលើសិទ្ធិទទួលបានលំនៅឋានសមរម្យ និងសិទ្ធិជាច្រើនផ្សេងទៀត ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ រួមទាំងសិទ្ធិមានសន្តិសុខផ្ទាល់ខ្លួន និងសិទ្ធិជនជាតិដើមភាគតិចចំពោះទឹកដី និងខណ្ឌសីមាជាលក្ខណៈប្រពៃណី

---

[3] ម.ស.ម.ក សលាកប័ត្រព័ត៌មាន ៖ ការបណ្តេញចេញដោយបង្ខំនៅកម្ពុជា ខែតុលា ឆ្នាំ២០២០

[4] ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស «ហាមឃាត់ការបណ្តេញចេញក្នុងអំឡុងពេលជំងឺរាតត្បាតកូវីដ១៩- ការជំរុញរបស់អ្នកជំនាញនៃ អ.ស.ប» ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២០។

[5] ធនាគារពិភពលោក 'បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា' ខែមិថុនា ឆ្នាំ២០២២ ទំព័រ១។

របស់ពួកគេ។[6] យោងតាមច្បាប់អន្តរជាតិ ការបណ្តេញចេញដោយបង្ខំ គឺអាចអនុញ្ញាតបានតែក្នុងកាលៈទេសៈមួយដែលមានកម្រិត និងតូចចង្អៀត ហើយត្រូវតែមានហេតុផលពេញលេញ និងអនុញ្ញាតដោយច្បាប់។ ការផ្តល់សំណង និងដំណោះស្រាយតាមផ្លូវច្បាប់ពេញលេញ ត្រូវតែមានសម្រាប់អ្នកដែលរងផលប៉ះពាល់។[7] កិច្ចការទាំងនោះគឺជាទំនួលខុសត្រូវរបស់រដ្ឋ ដើម្បីការពារពីការបណ្តេញចេញដោយបង្ខំ និងដើម្បីធានាថាការ បណ្តេញចេញត្រូវបានអនុញ្ញាតដោយច្បាប់ស្តីពីសិទ្ធិមនុស្ស និងត្រូវអនុវត្តក្នុងលក្ខខណ្ឌសមស្របបំផុត រួមទាំងការពិចារណាទៅលើជម្រើសផ្សេងៗ ការអនុវត្តតាមនីតិវិធីត្រឹមត្រូវ និងការគោរពសិទ្ធិទទួលបានព័ត៌មានពេញលេញ និងការពិគ្រោះយោបល់ត្រឹមត្រូវ និងការយល់ព្រមដោយពេញចិត្ត ដោយបានប្រាប់ឱ្យដឹងជាមុន ពីប្រជាពលរដ្ឋដែលរងផលប៉ះពាល់។ រដ្ឋត្រូវចាត់វិធានការចាំបាច់ទាំងអស់ផងដែរ ដើម្បីកាត់បន្ថយផលប៉ះពាល់ពីការបណ្តេញចេញ ដោយធានាថាពួកគេនឹងមិនក្លាយជាអ្នកគ្មានផ្ទះសម្បែងរស់នៅនោះទេ[8] និងធានាថាប្រជាពលរដ្ឋដែលត្រូវបានបណ្តេញចេញ ត្រូវទទួលបានសំណងគ្រប់គ្រាន់ជាមុន និងដំណោះស្រាយសមស្រប។[9]

រដ្ឋក៏ត្រូវមានការទទួលខុសត្រូវផងដែរ ដើម្បីការពារពីការបណ្តេញចេញដោយបង្ខំដែលប្រព្រឹត្តឡើងដោយភាគីទីបី ខណៈដែលធុរកិច្ចទាំងឡាយត្រូវមានកាតព្វកិច្ចគោរពសិទ្ធិមនុស្ស ដោយមិនត្រូវបណ្តេញប្រជាពលរដ្ឋចេញដោយបង្ខំនោះទេ។[10] ជាការសំខាន់ផងដែរក្នុងការរំលឹកថា ការការពារពីការបណ្តេញចេញដោយបង្ខំ មិនសំដៅតែទៅលើសុវត្ថិភាពកាន់កាប់ដីធ្លីរបស់បុគ្គលម្នាក់នោះទេ ប៉ុន្តែត្រូវធានាចំពោះបុគ្គលទាំងអស់រួមទាំងអ្នកទាំងឡាយដែលរស់នៅលើទីតាំងមិនទាន់ផ្លូវការ ទីជនបទ និងអ្នកជួលផងដែរ។[11]

## ខ. ក្របខណ្ឌច្បាប់

ការការពារពីការបណ្តេញចេញដោយបង្ខំ មានចែងក្នុងសន្ធិសញ្ញានៃកាតព្វកិច្ចតាមផ្លូវច្បាប់ ដែលបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជា រួមមានកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ («ក.អ.ស.ស.ស.វ») និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ ពលរដ្ឋ និងនយោបាយ («ក.អ.ស.ព.ន»)។[12]

**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មាត្រា១១**

«រដ្ឋជាភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិរបស់ជនគ្រប់រូបក្នុងការទទួលបានកម្រិតជីវភាពគ្រប់គ្រាន់សម្រាប់ខ្លួនផ្ទាល់ និងសម្រាប់គ្រួសារខ្លួន រួមមានចំណីអាហារ សំលៀកបំពាក់ និងទីលំនៅគ្រប់គ្រាន់ ព្រមទាំងការរីកចម្រើនជាលំដាប់នៃលក្ខខណ្ឌរស់នៅរបស់គេ»។

**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ មាត្រា១៧**

«គ្មានជនណាម្នាក់ ត្រូវទទួលរងការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ក្នុងជីវិតឯកជន គ្រួសារ លំនៅឋាន សំបុត្រឆ្លងឆ្លើយរបស់ខ្លួន ឬត្រូវរងការប៉ះពាល់ដោយខុសច្បាប់ទៅលើកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយ»។

(អូ.អេច.ស៊ី.អេច.អ ២០១៥) ទំព័រ ២៩។

[10] អូ.អេច.ស៊ី.អេច.អ «បទដ្ឋានសិទ្ធិដីធ្លី និងសិទ្ធិមនុស្ស និងការអនុវត្ត» (លេខ២៦) ទំព័រ ៨១។

[11] ប្រភពដូចខាងលើ ទំព័រ៧។

[12] សម្រាប់ព័ត៌មានបន្ថែមអំពីសិទ្ធិមនុស្ស និងកាតព្វកិច្ចរបស់រដ្ឋក្រោមច្បាប់អន្តរជាតិពាក់ព័ន្ធនឹងការបណ្តេញចេញដោយបង្ខំ សូមមើលអ្នករាយការណ៍ពិសេសស្តីពីលំនៅឋានសមរម្យ »គោលការណ៍ជាមូលដ្ឋាន និងមគ្គុទេសក៍ស្តីពីការបណ្តេញចេញ និងការផ្លាស់ទីលំនៅដោយផ្អែកលើការអភិវឌ្ឍន៍» (អូ.អេច.ស៊ី.អេច.អ ២០០៧) ឯកសារ យូ.អិន អេ/អេច.អ.ស៊ី/៤/១៨។

សន្ធិសញ្ញាសិទ្ធិមនុស្សទាំងនេះ **ត្រូវបានដាក់បញ្ចូលដោយផ្ទាល់នៅក្នុងច្បាប់ជាតិ** តាមរយៈមាត្រា៣១ នៃរដ្ឋធម្មនុញ្ញ។ ច្បាប់ជាតិក៏ផ្តល់ការការពារជាច្រើនពីការបណ្តេញចេញដោយបង្ខំ។ រដ្ឋធម្មនុញ្ញ និងច្បាប់ភូមិបាលឆ្នាំ ២០០១ បានចែងថាការដកហូត **ដីធ្លី/អចលនវត្ថុ អាចអនុវត្តទៅបានតែក្នុងករណីផ្តល់ផលប្រយោជន៍សាធារណៈប៉ុណ្ណោះ និងដោយតម្រូវឱ្យផ្តល់សំណងត្រឹមត្រូវ និងយុត្តិធម៌ជាមុន។**[13] ច្បាប់ភូមិបាល ផ្តល់សិទ្ធិភោគៈ និងសិទ្ធិក្នុងការស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លីបន្ថែមទៀតក្នុងកាលៈទេសៈជាក់លាក់[14] និងមានបទប្បញ្ញត្តិការពារពីការបណ្តេញចេញដោយបង្ខំដែលប្រព្រឹត្តដោយម្ចាស់ និងអ្នកកាន់កាប់ឯកជន។[15] ច្បាប់ស្តីពីអស្សាមិករណ៍ឆ្នាំ ២០១០ ក៏បង្ហាញអំពីតម្រូវការសម្រាប់សំណងសមរម្យផងដែរ។

នៅក្នុងឆ្នាំ ២០០២ រាជរដ្ឋាភិបាលបានប្តេជ្ញាថានឹង «បញ្ជាក់ និងកត់ត្រាកម្មសិទ្ធិ និងសិទ្ធិផ្សេងទៀត ដើម្បីពង្រឹងសុវត្ថិភាពកាន់កាប់ដីធ្លី បង្កើនប្រសិទ្ធភាព និងភាពជឿជាក់នៃទីផ្សារដីធ្លី និងការពារសុខដុមរមនាក្នុងសង្គមដោយការទប់ស្កាត់ ឬដោះស្រាយវិវាទដីធ្លី»។[16] រាជរដ្ឋាភិបាលក៏បានបង្កើតក្របខ័ណ្ឌច្បាប់ គោលនយោបាយ និងស្ថាប័ន ដើម្បីអនុវត្តច្បាប់ភូមិបាលឆ្នាំ២០០១។ ក្របខណ្ឌទាំងនេះទទួលស្គាល់ និងផ្តល់ការការពារសំខាន់ដើម្បីការពារសិទ្ធិកាន់កាប់ដីធ្លី ក៏ដូចជាសិទ្ធិភោគៈ និងសិទ្ធិកម្មសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជា រួមទាំងការការពារពួកគាត់ពីការបណ្តេញចេញដោយបង្ខំ។ នៅក្រោមគោលនយោបាយទាំងនេះ ការបណ្តេញចេញដោយបង្ខំគឺខុសច្បាប់ ហើយការតាំងទីលំនៅថ្មីអាចប្រព្រឹត្តទៅបានលុះត្រាតែជាជម្រើសចុងក្រោយប៉ុណ្ណោះ។[17]

## ២. ករណីបណ្តេញចេញដោយបង្ខំថ្មីៗមួយចំនួននៅកម្ពុជា

ការបណ្តេញចេញដោយបង្ខំមិនបានបង្ហាញពីសញ្ញានៃការថមថយឡើយ ចាប់តាំងពីប្រទេសនេះបានដកការរឹតបន្តឹងអំឡុងពេលជំងឺ កូវីដ-១៩ តាំងចុងឆ្នាំ២០២១ មក ទោះបីជាមានការជំរុញនៃការផ្តល់ប័ណ្ណកម្មសិទ្ធិនាពេលថ្មីៗនេះដែលបង្ហាញថារាជរដ្ឋាភិបាលបានផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជិត ៦,៩ លានប័ណ្ណ (គិតត្រឹមខែមិថុនា ឆ្នាំ២០២៣ ឆ្លើយតបនឹងគោលបំណងរួមនៃការចេញប័ណ្ណកម្មសិទ្ធិចំនួន ៧ លានប័ណ្ណឱ្យទាន់នៅចុងឆ្នាំ២០២៣)។[18] ទោះបីជាជនជាតិដើមភាគតិចបានទទួលរងផលប៉ះពាល់ជាប្រវត្តិសាស្ត្រ ក្នុងការបណ្តេញ

---

[13] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ មាត្រា ៤៤ សូមមើលផងដែរ៖ ច្បាប់ភូមិបាលឆ្នាំ ២០០១ មាត្រា ៥។

[14] ឧទាហរណ៍ មាត្រា ៣០ នៃច្បាប់ភូមិបាលឆ្នាំ ២០០១ ផ្តល់សិទ្ធិក្នុងការស្នើសុំប័ណ្ណកម្មសិទ្ធិច្បាស់លាស់សម្រាប់អ្នកដែលមានការកាន់កាប់ដីដោយសន្តិវិធី គ្មានជម្លោះដីធ្លី ឬលំនៅឋានចាប់ពី ៥ ឆ្នាំឡើងទៅ មុនពេលច្បាប់នេះប្រកាសឱ្យប្រើ។

[15] មើលច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា២៥៤។

[16] «ការបណ្តេញចេញ និងការតាំងលំនៅថ្មីនៅក្នុងប្រទេសកម្ពុជា» (អូ.អេច.ស៊ី.អេច.អ ២០១២) ទំព័រ២

[17] គោលការណ៍នេះ ត្រូវបានបញ្ជាក់ជាថ្មីដោយ ឯកឧត្តម អ៊ឹម ឈុន លឹម ទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ នៅពេលដែលឯកឧត្តម បានទទួលជួបពិភាក្សាជាមួយលោកស្រី យ៉ុង ហ្វា កាំង ឧត្តមស្នងការរង អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១០។ អូ.អេច.ស៊ី.អេច.អ «ការបណ្តេញចេញ និងការតាំងលំនៅថ្មីនៅក្នុងប្រទេសកម្ពុជា តម្លៃនៃផលប៉ះពាល់ជាអវិជ្ជមានចំពោះមនុស្ស ឥទ្ធិពល និងដំណោះស្រាយ។» ២០១២ ទំព័រ២។

[18] យោងតាមតួលេខជាផ្លូវការរបស់រាជរដ្ឋាភិបាល សូមមើល តំណភ្ជាប់នេះ ទំព័រ៧។

ចេញដោយបង្ខំដោយសារការផ្តល់សម្បទានដីសេដ្ឋកិច្ច និងការទន្ទ្រានយកដីព្រៃពណីរបស់ពួកគេដោយតួអង្គធុរជនយ៉ាងណាក្តី ក៏ការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់ពួកគេមានការវិវត្តតិចតួចប៉ុណ្ណោះ។[19]

តាមការប៉ាន់ប្រមាណ បញ្ហានេះបានធ្វើឱ្យជនជាតិដើមភាគតិចក្នុងចំណោម ១៦៤.៥៤១ នាក់ ប្រឈមនឹងហានិភ័យនៃការបណ្តេញចេញដោយបង្ខំ។[20]

ចាប់ពីខែមីនា ឆ្នាំ ២០២០ ដល់ខែសីហា ឆ្នាំ ២០២៣ គម្រោងធុរកិច្ចនិងសិទ្ធិមនុស្សរបស់ ម.ស.ម.ក បានកត់ត្រាទុកនូវអត្ថបទពីប្រព័ន្ធផ្សព្វផ្សាយនានាដែលផ្តោតតែទៅលើការបណ្តេញចេញដោយបង្ខំ សរុបចំនួន ២២ ករណី ក្នុងនោះមានប្រជាពលរដ្ឋប្រមាណចំនួន ១៣.១១១ គ្រួសារដែលត្រូវបានបណ្តេញចេញ និងកំពុងប្រឈមនឹងការបណ្តេញចេញនៅក្នុងខេត្ត-ក្រុង-រាជធានី ចំនួន១១ គឺ (រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តកំពង់ឆ្នាំង ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី)។ ដោយផ្អែកទៅលើចំនួនសមាជិកគ្រួសារកម្ពុជាជាមធ្យម ការបណ្តេញចេញដោយបង្ខំអាចពាក់ព័ន្ធនឹងប្រជាពលរដ្ឋចំនួនប្រមាណជាង ៥៧.០៣២ នាក់។[21] ការបណ្តេញចេញដោយបង្ខំនាពេលថ្មីៗនេះ ដែលកត់ត្រាដោយ ម.ស.ម.ក ត្រូវបានសម្គាល់ថាមាន**ការប្រើប្រាស់កម្លាំង ការគំរាមកំហែង ឬការបំភិតបំភ័យ ការបំផ្លិចបំផ្លាញផ្ទះសម្បែង និងដីស្រែចម្ការដោយគ្មានការជូនដំណឹងជាមុន** ពីមន្ត្រី ឬក្រុមហ៊ុនឯកជន **កញ្ចប់សំណងមិនសមរម្យ** និងខ្វះការពិគ្រោះយោបល់ជាទូទៅជាមួយសហគមន៍ដែលរងផលប៉ះពាល់។ ជនរងគ្រោះភាគច្រើនបំផុតគឺជា**សមាជិកសហគមន៍ក្រីក្រនៃទីក្រុង កសិករ និងក្រុមងាយរងគ្រោះ** រួមទាំងសហគមន៍ជនជាតិដើមភាគតិចផងដែរ។

## ក. ប្រជាពលរដ្ឋខេត្តសៀមរាបរាប់ពាន់គ្រួសារត្រូវបណ្តេញចេញពីឧទ្យានបុរាណវិទ្យាអង្គរ

ចាប់ពីខែវិច្ឆិកា ឆ្នាំ ២០២២ មក មានប្រជាពលរដ្ឋប្រហែល ៦.០០០ គ្រួសារបានផ្លាស់ទីលំនៅពីផ្ទះសម្បែងរបស់ពួកគាត់ដែលនៅជិតប្រាសាទអង្គរវត្ត ទៅឃុំរុនតាឯក ស្រុកបន្ទាយស្រី ដែលមានចម្ងាយប្រមាណ ៣០ គីឡូម៉ែត្រពីទីតាំងចាស់។[22] ការផ្លាស់ប្តូរនេះ គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងដើម្បីបោសសំអាតការតាំងទីលំនៅដែលរាជរដ្ឋាភិបាលនិយាយថាជាការបំផ្លាញបរិស្ថាន និងអាចប៉ះពាល់ដល់ស្ថានភាពបេតិកភណ្ឌពិភពលោករបស់ប្រាសាទអង្គរវត្ត។ សំដីដកស្រង់ពីមន្ត្រីបាននិយាថាក្នុងខែមេសា ឆ្នាំ២០២៣ នេះ មានប្រជាពលរដ្ឋប្រមាណ ១០.០០០ គ្រួសារបាន «ស្ម័គ្រចិត្ត» ផ្លាស់ប្តូរទីលំនៅ។[23] ប៉ុន្តែការស្រាវជ្រាវដែលចេញផ្សាយ

---

[19] ម.ស.ម.ក «បច្ចុប្បន្នភាពនៃការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពសម្រាប់សហគមន៍ជនជាតិដើមភាគតិចឆ្នាំ២០២៣»(ខែសីហា ឆ្នាំ២០២៣)។

[20] ការគណនាដែលយោងទៅលើតួលេខ៖ ក្រសួងផែនការ និងអភិវឌ្ឍន៍ជនបទ «របាយការណ៍ស្តីពីស្ថានភាពប្រជាសាស្ត្រ សង្គម និងសេដ្ឋកិច្ចនៃជនជាតិដើមភាគតិចនៃប្រទេសកម្ពុជា»។ »ឆ្នាំ ២០២១ ទំព័រ ៧២ និង xii; ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ "របាយការណ៍លទ្ធផល» ខែមិថុនា ឆ្នាំ ២០២៣ ទំព័រ ៧ ។

[21] ការគណនានេះផ្អែកលើការបញ្ជាក់ជាផ្លូវការដែលធ្វើឡើងដោយឯកឧត្តមទេសរដ្ឋមន្ត្រី ឆាយ ថន រដ្ឋមន្ត្រីក្រសួងផែនការ នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ ២០២៣។ សូមមើលអត្ថបទនេះពីសេវាព័ត៌មានអប្សរា សម្រាប់ព័ត៌មានលម្អិត។

[22] បុគ្គលិក ខេមបូចា គ្មានជម្រើស៖ «រដ្ឋាភិបាលធ្វើរបាយការណ៍ទៅអង្គការយូណេស្កូថាពលរដ្ឋស្ម័គ្រចិត្តរើចេញពីតំបន់អង្គរ ប៉ុន្តែពលរដ្ឋថាគ្មានជម្រើស»(អត្ថបទព័ត៌មានរបស់ ខេមបូចា ថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣)។

[23] ប្រភពខាងលើ។

ដោយអង្គការលើកលែងទោសអន្តរជាតិ ក្នុងខែមីនា ឆ្នាំ ២០២៣ បានបង្ហាញថា ប្រជាពលរដ្ឋទាំងនោះមានអារម្មណ៍ថាត្រូវបានបង្ខំឱ្យចាកចេញ។[24] ករណីនេះក៏ត្រូវបានបញ្ជាក់ដោយរបាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកផងដែរ។[25] អង្គការលើកលែងទោសអន្តរជាតិបានលើកបង្ហាញពីការខ្វះខាតរួមមាន «ការជូនដំណឹងមុនការបណ្ដេញចេញ និងការពិគ្រោះយោបល់ពេញលេញជាមួយសហគមន៍ដែលរងផលប៉ះពាល់អំពីដំណើរការបណ្ដេញចេញ និងការតាំងទីលំនៅថ្មី»។[26] គ្រួសារជាច្រើនដែលត្រូវបានបញ្ជូនទៅ រុន តាឯក ត្រូវ កសាងជីវភាពថ្មី និងមួយផ្នែកនៃថវិកាដែលបានផ្ដល់ឱ្យពួកគេគឺត្រូវចំណាយសម្រាប់សាងសង់ផ្ទះថ្មី តែពេលនេះពួកគេជួបប្រទះនឹងបញ្ហាជីវភាពរស់នៅបន្តទៀត។[27] នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៣ អង្គការលើកលែងទោសអន្តរជាតិបាននិយាយថា «ការបណ្ដេញចេញដោយបង្ខំដែលមានទំហំធំ» បែបនេះគឺ បណ្ដាលឱ្យមានការកើនឡើងនៃបំណុល និងភាពក្រីក្រសម្រាប់ប្រជាពលរដ្ឋជាច្រើន។[28]

ក្នុងករណីខ្លះ រាជរដ្ឋាភិបាលបានបែងចែកដីដែលសហគមន៍មូលដ្ឋានបានប្រើប្រាស់តាមបែបប្រពៃណីដើម្បីផ្ដល់ជាទីជម្រកដល់ប្រជាពលរដ្ឋដែលត្រូវបានបណ្ដេញចេញពីតំបន់អង្គរ រួមមានដូចជាផ្ទៃដីទំហំ ៥១៤ ហិកតា នៅក្នុងភូមិចំនួនបីនៃឃុំពើកស្លែង ស្រុកអង្គរធំ។ ប្រជាពលរដ្ឋប្រមាណ ២០០នាក់ មកពីភូមិមួយក្នុងចំណោមភូមិទាំងនោះ ត្រូវបានផ្ដល់ដីតូចៗនៅទីតាំងដែលមិនច្បាស់លាស់ ជាថ្នូរនឹងការបាត់បង់ដីកសិកម្មរបស់ពួកគេដែលត្រូវផ្ដល់ទៅឱ្យប្រជាពលរដ្ឋដែលត្រូវបានបណ្ដេញចេញពីតំបន់អង្គរនោះ។ មានព័ត៌មានថាពួកគេនឹងមិនទទួលបានអ្វីទាំងអស់ប្រសិនបើពួកគេបដិសេធដីដែលដោះដូរនោះ។[29] កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ ២០២២ មេភូមិម្នាក់ក្នុងឃុំបល្ល័ង្ក ស្រុកប្រាសាទបាគង ត្រូវបានដកចេញពីតំណែង បន្ទាប់ពីព្យាយាមចូលរួមការតវ៉ាដែលរៀបចំឡើងដោយប្រជាពលរដ្ឋជាង ២០០គ្រួសារ នៅ រុនតាឯក ដែលបាតវ៉ានឹងការដកហូតអតីតដីស្រែរបស់ពួកគេទៅឱ្យប្រជាពលរដ្ឋដែលត្រូវបានបណ្ដេញចេញពីតំបន់អង្គរ។[30]

## ខ. ប្រជាពលរដ្ឋជាច្រើនរយគ្រួសារកំពុងរស់នៅលើដីរបស់រដ្ឋត្រូវបានបង្ខំឱ្យប្ដូរទីលំនៅ

តាមរយៈរបាយការណ៍ចេញផ្សាយក្នុងខែកញ្ញាឆ្នាំ២០២៣ របស់អង្គការសមាគមធាងត្នោតបានលើកឡើងថា មាន**ទីតាំងលំនៅឋានក្រីក្រ**ចំនួនសរុប១៩១ទីតាំង ក្នុងរាជធានីភ្នំពេញ ចំនួននេះបានធ្លាក់ចុះជាងក្នុងឆ្នាំ២០១៧ ដែលមាន២៧៧ទីតាំង។ ជិត ៧០ ភាគរយនៃគ្រួសារពលរដ្ឋដែលរស់នៅលើតាំងទីលំឋានក្រីក្រទាំងនេះបានលើកឡើងថាពួកគាត់ពុំមានឯកសារដីធ្លីផ្លូវការនោះទេ ដែលធ្វើឱ្យពួកគាត់ងាយប្រឈមខ្លាំងទៅ

[24] អង្គការលោកលែងទោសអន្តរជាតិ «កម្ពុជា៖ បញ្ឈប់ "ការបណ្ដេញចេញដោយបង្ខំ" នៅតំបន់អង្គរវត្ត ដែលជាបេតិកភណ្ឌពិភពលោក» (ថ្ងៃទី៣១ ខែមិនា ឆ្នាំ២០២៣)

[25] ប្រពភដូចបានដាក់បង្ហាញនៅលេខយោង២២ ខាងលើ

[26] ប្រពភដូចបានដាក់បង្ហាញនៅលេខយោង២៤ ខាងលើ

[27] ប្រពភដូចបានដាក់បង្ហាញនៅលេខយោង២២ ខាងលើ

[28] អង្គការលើកលែងទោសអន្តរជាតិ «កម្ពុជា៖ គណៈកម្មាធិការបេតិកភណ្ឌពិភពលោក មិនត្រូវព្រងើយកន្តើយចំពោះការបណ្ដេញចេញដោយបង្ខំជុំវិញប្រាសាទអង្គរវត្តឡើយ»។

[29] ប្រពភដូចបានដាក់បង្ហាញនៅលេខយោង២២ ខាងលើ

[30] យុត សុគុន្ធ «មេភូមិត្រូវបណ្ដេញចេញបន្ទាប់ពីចូលរួមការតវ៉ាក្នុងការប្ដូរទីតាំងពីតំបន់អង្គរ» (វិទ្យុសម្លេងប្រជាធិបតេយ្យ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ ២០២២)

នឹងការបណ្តេញចេញដោយបង្ខំ។ មានការរាយការណ៍ថាទីតាំងលំនៅឋានក្រីក្រចំនួន ៥៦ ទីតាំង (២៩% ក្នុងចំណោមទីតាំងសរុប) កំពុងប្រឈមនឹងការបណ្តេញចេញ និង/ឬរងសម្ពាធឱ្យធ្វើការប្តូរទីតាំង ដែលចំនួននេះបានកើនឡើងជាងឆ្នាំ២០១៧ ដែលមានតែ៤១ទីតាំង។ អង្គការសមាគមធាងត្នោតបានលើកឡើងថាសម្ពាធដែលកើនឡើងនេះ គឺដោយសារគោលនយោបាយរបស់រដ្ឋាភិបាលដែលផ្តល់អាទិភាពលើការផ្តល់សម្បទានដីសាធារណៈដល់ក្រុមហ៊ុនឯកជននិងបុគ្គលមួយចំនួន។ របាយការណ៍នោះ បានបន្ថែមថាតិចជាងមួយភាគបួននៃទីតាំងលំនៅឋានដែលប្រឈមនឹងការបណ្តេញចេញទាំងនោះ ទទួលបានការជូនដំណឹងជាផ្លូវការ។[31]

នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ អាជ្ញាធរខណ្ឌព្រែកព្នៅបានចុះរុះរើលំនៅឋានរបស់ប្រជាពលរដ្ឋចំនួន ១១គ្រួសារដែលរស់នៅតាមមាត់ច្រាំងនៃបឹងតាមោក បន្ទាប់ពីគ្រួសារទាំងនោះបដិសេធទទួលយកសំណងជាកញ្ចប់ផ្តល់ដោយរដ្ឋាភិបាលជាថ្នូរនឹងការប្តូរទីលំនៅ។ ប្រជាពលរដ្ឋបានរាយការណ៍ថា មានប្រជាពលរដ្ឋចំនួន ១២គ្រួសារបានទទួលយកសំណងដោយការភ័យខ្លាចពីការធ្វើទុក្ខបុកម្នេញពីសំណាក់អាជ្ញាធរ។[32] ការចាក់ដីលុបបឹងតាមោក ជាបឹងធម្មជាតិធំជាងគេក្នុងរាជធានីភ្នំពេញ ដើម្បីធ្វើការអភិវឌ្ឍផ្នែកអចលនទ្រព្យបាននាំឱ្យមានការបណ្តេញចេញប្រជាពលរដ្ឋជាច្រើនរយគ្រួសាររួចទៅហើយគិតនៅត្រឹមចុងឆ្នាំ ២០២២។ មានប្រជាពលរដ្ឋចំនួន២៥០ គ្រួសារថែមទៀត ប្រមាណចំនួន១.២០០នាក់កំពុងប្រឈមនឹងការបណ្តេញចេញ។[33]

មិនត្រឹមតែប៉ុណ្ណោះ ក្នុងខែកក្កដា ឆ្នាំ២០២២ ប្រជាពលរដ្ឋជាង៣០០គ្រួសារ រស់នៅក្នុង***ខណ្ឌឫស្សីកែវ*** បានទទួលការជូនដំណឹងពីការបណ្តេញចេញដោយបង្គាប់ឱ្យពួកគាត់ចាកចេញពីផ្ទះសម្បែងដែលស្ថិតនៅលើដីរបស់រដ្ឋដើម្បីបើកផ្លូវសម្រាប់គម្រោងធ្វើការកែលម្អទីក្រុង។ ក្នុងរយៈពេលច្រើនខែបន្ទាប់មក អាជ្ញាធរបានដាក់សម្ពាធលើពលរដ្ឋទាំងនោះឱ្យចាកចេញដោយគំរាមចាប់ខ្លួន ហើយបានចាប់ផ្តើមបំផ្លិចបំផ្លាញលំនៅឋានរបស់ពួកគាត់ដោយពុំមានការយល់ព្រម។[34] ប្រជាពលរដ្ឋបានលើកឡើងថាពួកគាត់ធ្លាប់រងការព្រមានថាពួកគាត់កំពុងរស់នៅខុសច្បាប់លើដីរដ្ឋនាពេលកន្លងមក ប៉ុន្តែពួកគាត់បានលើកឡើងថាពុំមានលទ្ធភាពក្នុងការរើទៅកាន់ទីតាំងផ្សេងទេ។[35] ទោះយ៉ាងណាក្តី ពួកគាត់បានទទួលសំណងផ្តល់ចន្លោះពី ២៥០ ដុល្លារអាម៉េរិក ដល់ ៧៥០ ដុល្លារអាម៉េរិក ហើយមានការចរចាបង្កើនចំនួនប្រាក់សំណងតែពុំទទួលជោគជ័យ។[36] នៅទីបំផុតប្រជាពលរដ្ឋភាគច្រើនពុំមានជម្រើសក្រៅតែពីការប្តូរទីលំនៅដោយស្នាក់ស្នើរទៅកាន់ឃុំសំរោង ខណ្ឌព្រែកព្នៅ ដែលមានចំងាយប្រមាណ១០គីឡូម៉ែត្រនោះទេ។ ក្នុងខែកញ្ញា ឆ្នាំ២០២២ រដ្ឋាភិបាលបានចុះហត្ថលេខាលើ

[31] អង្គការសមាគមធាងត្នោត [របាយការណ៍ការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០២៣: ស្តីពី ការសិក្សាទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុងភ្នំពេញ] (ខែកញ្ញា ឆ្នាំ២០២៣)

[32] តេង យ៉ាលីហ្ស៊ី « អាជ្ញាធរបណ្តេញប្រជាពលរដ្ឋដែលរស់នៅលើច្រាំងបឹងតាមោក» (ខេមបូឌាណេស) ខែ២៨ ខែកុម្ភៈ ឆ្នាំ២០២២)

[33] ហ្វីអូណា កេលីហើ និង ម៉ិច ដារា « ហេតុអ្វីបានជាយើងគ្មានសិទ្ធិ» សហគមន៍នៅបឹងតាមោកនៅតែតវ៉ាជំទាស់នឹងក្រុមហ៊ុនអភិវឌ្ឍន៍រហូតដល់ដំណាក់កាលចុងក្រោយ (ហ្គាឌៀន) ៨ វិច្ឆិកា ២០២២)

[34] នាង សុគន្ធា « ក្រុមហ៊ុនឯកជនទទួលបានដីជាប់មាត់ទន្លេជិត១៣ហិកតា ពលរដ្ឋជាង៣០០គ្រួសារប្រឈមការបណ្តេញចេញ» (សារព័ត៌មានខេមបូចា ១៦ មីនា ២០២៣)

[35] ង៉ៃណៃ « ការបណ្តេញចេញដោយបង្ខំចាប់ផ្តើមលើប្រជាពលរដ្ឋរស់នៅទន្លេសាប» (សារព័ត៌មានខេមបូចា ២០ កក្កដា ២០២២)

[36] វី រួន « គ្រួសាររស់នៅតាមដងទន្លេនៅឫស្សីកែវចង់បានសំណងយុត្តិធម៌មុនពេលចាកចេញ» (វីអូឌី ២១ កក្កដា ២០២២)

អនុក្រឹត្យមួយផ្តល់ដីទំហំ ១២,៩៨ ហិកតា ជាទីតាំងដែលប្រជាពលរដ្ឋទាំងនោះធ្លាប់បានតាំងទីលំនៅឱ្យទៅក្រុមហ៊ុនឯកជនមួយ។[37]

## គ. ការសាងសង់ព្រលានយន្តហោះអន្តរជាតិថ្មីនៅខេត្តកណ្តាល

ការសាងសង់ព្រលានយន្តហោះអន្តរជាតិថ្មីនៅខេត្តកណ្តាលដែលបានចាប់ផ្តើមក្នុងឆ្នាំ២០១៩ នឹងនាំឱ្យមានការបន្លាស់ទីប្រជាពលរដ្ឋជាង៤០០គ្រួសារក្នុងខេត្តកណ្តាល និងខេត្តតាកែវ។[38] ក្រុមហ៊ុនសាជីវកម្មវិនិយោគក្រៅប្រទេសកម្ពុជា («អូស៊ីអាយស៊ី») ដែលទទួលបន្ទុកលើគម្រោងសាងសង់ បានផ្តល់សំណងក្នុងតម្លៃ ៨ ដុល្លារអាម៉េរិក ក្នុងមួយម៉ែត្រការ៉េដល់សហគមន៍ដែលរងផលប៉ះពាល់ ដែលស្មើប្រមាណត្រឹមតែមួយភាគដប់នៃតម្លៃទីផ្សា។ ប៉ុន្តែ គ្រួសារមួយចំនួនបានបដិសេធការផ្តល់នេះព្រោះទាបខ្លាំងពេក។[39] តែយ៉ាងណាក្តី នៅថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០២២ គ្រឿងចក្រជាច្រើនត្រូវបានដាក់ពង្រាយដើម្បីឈូសឆាយដីស្រែ និងដីទំនាបជាកម្មសិទ្ធិរបស់អ្នកភូមិនៅក្នុងឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង។ អភិបាលស្រុកបានបញ្ជូនមន្ត្រីនគរបាល និងកងរាជអាវុធហត្ថចុះមកកាន់ទីតាំងនោះ ដោយអះអាងថាជាការចាំបាច់ដើម្បីទប់ស្កាត់ជម្លោះ និងធានាថាបទបញ្ជាដែលដាក់ចេញដោយអាជ្ញាធរមូលដ្ឋានត្រូវបានអនុវត្ត។[40]

នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២ ក្រុមហ៊ុនអូស៊ីអាយស៊ីបានចាប់ផ្តើមឈូសឆាយដីស្រែដោយពុំមានការជូនដំណឹងនៅតាខ្មៅដើម្បីបើកផ្លូវសម្រាប់សាងសង់ផ្លូវ ទោះបីជាដីមានទំនាស់នោះពុំទាន់បានដោះស្រាយជាមួយគ្រួសារនៅក្នុងតំបន់ចំនួន ៦ គ្រួសារនោះក្តី។ ការឈូសឆាយបានផ្អាកវិញបន្ទាប់ពីអាជ្ញាធរមូលដ្ឋានបានអន្តរាគម និងទុករយៈពេលពីរបីថ្ងៃថែមទៀតដល់ប្រជាពលរដ្ឋសម្រាប់ការចរចា។[41] នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ ២០២៣ មានការរាយការណ៍ថាក្រុមហ៊ុន អូស៊ីអាយស៊ីបានចាប់ផ្តើមចរចាដោយផ្ទាល់ជាមួយប្រជាពលរដ្ឋមួយចំនួនក្នុងចំណោមប្រជាពលរដ្ឋជាង៦០គ្រួសារនៅភូមិកំពង់តាឡុង ដែលនៅតែរក្សាការទាមទារសំណងប្រសើរជាងនេះ។[42] នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣ ប្រជាពលរដ្ឋជាង៥០០គ្រួសារមកពីភូមិចំនួន៤ ក្នុងឃុំ

---

[37] នាង សុគន្ធា « ក្រុមហ៊ុនឯកជនទទួលបានដីជាប់មាត់ទន្លេជិត១៣ហិកតា ពលរដ្ឋជាង៣០០គ្រួសារប្រឈមការបណ្តេញចេញ»(សារព័ត៌មានខេមបូចា ១៦ មីនា ២០២៣)

[38] ស៊ិន សារ៉ាត «គ្រួសារពលរដ្ឋនៅខេត្តកណ្តាលដែលប្រឈមនឹងការបណ្តេញចេញពីទីតាំងព្រលានយន្តហោះស្នើសុំប័ណ្ណដីធ្លី» (សារព័ត៌មានខេមបូចា ០៨ កុម្ភៈ ឆ្នាំ២០២៣

[39] ស៊ិន សារ៉ាត « គម្រោងអភិវឌ្ឍន៍ព្រលានយន្តហោះដ៏ធំនៅតែបន្ត ទោះបីជាមានការប្រឆាំងពីពលរដ្ឋមូលដ្ឋាន» (សារព័ត៌មានខេមបូចា ១២ មីនា ២០២២)

[40] យួន ណារីម «ការឈូសឆាយដីរបស់ប្រជាពលរដ្ឋសម្រាប់គម្រោងព្រលានយន្តហោះដ៏ធំ ទោះបីជាទំនាស់នៅតែបន្តកើតឡើង»សារព័ត៌មានខេមបូចា ១០ កុម្ភៈ ២០២២)

[41] ស៊ិន សារ៉ាត « ក្រុមហ៊ុនអភិវឌ្ឍន៍ព្រលានយន្តហោះថ្មីចាប់ផ្តើមឈូសឆាយដីស្រែ ទោះបីជាពុំទាន់មានការឯកភាពលើសំណង» (សារព័ត៌មានខេមបូចា ១០ មេសា ឆ្នាំ២០២២)

[42] ស៊ិន សារ៉ាត រុន ស្រីដេត « ក្រុមហ៊ុនសាងសង់ព្រលានយន្តហោះចាប់ផ្តើមការចរចាផ្ទាល់ជាមួយគ្រួសារដែលស្វែងរកសំណងប្រសើរ» (សារព័ត៌មានខេមបូចា ១៩ មេសា ២០២៣)

កណ្តោក ស្រុកកណ្តាលស្ទឹង និងសង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅបានដាក់ញត្តិទៅអភិបាលខេត្ត ស្នើឱ្យអាជ្ញាធរផ្តល់ប័ណ្ណកម្មសិទ្ធិដីដល់ពួកគាត់ និងសិទ្ធិបន្តការរស់នៅលើដីរបស់ខ្លួន។ អ្នកភូមិម្នាក់បានរាយការណ៍ថាអ្នកស្រីបានបដិសេធប្តូរទៅកាន់ទីតាំងថ្មី ពីព្រោះនឹងធ្វើឱ្យគ្រួសាររបស់អ្នកស្រីកាន់តែក្រីក្រ។[43]

## ករណីផ្សេងៗ ដែល ម.ស.ម.ក បានកត់ត្រាចាប់តាំងពីឆ្នាំ២០២២ រួមមាន៖[44]

**ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ - ខេត្តកំពង់ស្ពឺ:** ទាហានបានបាញ់កាំភ្លើងព្រមាន និងវាយដំលើអ្នកភូមិដែលបានព្យាយាមរារាំងការឈូសឆាយដីព្រៃដែលមានវិវាទក្នុងឃុំត្រពាំងជោរ ស្រុកឱរ៉ាល់ ដែលបង្កឱ្យអ្នកភូមិចំនួន ៣ នាក់រងរបួស។ ដីព្រៃដែលស្ថិតនៅក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់នេះ ត្រូវបានផ្តល់ទៅឱ្យយោធាក្នុងឆ្នាំ២០២១ដើម្បីកាប់ឆ្ការធ្វើជាទីតាំងលំនៅឋានរបស់គ្រួសារយោធា។ ករណីនេះ ពុំមានការជូនដំណឹងដល់ប្រជាពលរដ្ឋចំនួន ២៥៣ គ្រួសារ ដែលបានរងផលប៉ះពាល់ដោយសេចក្តីសម្រេចនោះទេ។ អ្នកភូមិម្នាក់បាននិយាយថាក្រុមមន្ត្រីបានគំរាមបាញ់អ្នកដែលតវ៉ានឹងការកាប់ឆ្ការក្នុងតំបន់នោះ។ មានការលើកឡើងថាក្រុមទាហានបានវាយដំលើអ្នកភូមិម្នាក់ផ្សេងទៀតក្នុងខែមីនា ឆ្នាំ២០២២ ព្រមទាំងបានបាញ់កាំភ្លើងព្រមានព្រះតេជគុណ ព្រហ្មធម្មជាតិ សហស្ថាបនិកក្រុមមាតាធម្មជាតិទៀតផង។[45]

**ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ - ខេត្តព្រះវិហារ:** អាជ្ញាធរមូលដ្ឋានបានបណ្តេញប្រជាពលរដ្ឋប្រមាណ ៣០០គ្រួសារ ដែលភាគច្រើនគឺជាជនជាតិដើមភាគតិចគួយនៅស្រុកគូលែន ដោយអះអាងថាប្រជាពលរដ្ឋទាំងនោះកំពុងរស់នៅលើដីរដ្ឋ។ ចាប់តាំងពីឆ្នាំ២០១២ មក គ្រួសារពលរដ្ឋទាំងនោះបានជាប់ពាក់ព័ន្ធក្នុងទំនាស់ដីធ្លីជាមួយក្រុមហ៊ុនស្ករអំពៅចិនហេងហ្វូដែលទទួលបានដីសម្បទានសេដ្ឋកិច្ចទំហំជាង៤០.០០០ហិកតាក្នុងតំបន់នោះ។ គ្រួសារពលរដ្ឋទាំងនោះបានព្យាយាមស្វែងរកដំណោះស្រាយដែរ ប៉ុន្តែអាជ្ញាធរមូលដ្ឋានមិនអើពើ។ នៅទីបំផុតពួកគាត់បានបង្ខំចិត្តប្តូរទីលំនៅទៅកាន់ទីតាំងផ្សេងនៃព្រៃក្នុងតំបន់នោះ ពីព្រោះពួកគាត់គ្មានកន្លែងផ្សេងរស់នៅឡើយ។[46]

---

[43] ស៊ន សារ៉ាត រុន ស្រីដេត «គ្រួសារពលរដ្ឋនៅខេត្តកណ្តាល៥០០គ្រួសារដាក់ញត្តិទៅអាជ្ញាធរឱ្យបញ្ឈប់ការបណ្តេញចេញដើម្បីគម្រោងសាងសង់ព្រលានយន្តហោះ» (សារព័ត៌មានខេមបូចា ២៤ មេសា ២០២៣)

[44] ករណីដែលលើកឡើងក្នុងសលាកបត្រព័ត៌មាននេះមិនមែនជាបញ្ជីទាំងស្រុងនៃករណីដែលបានកត់ត្រាដោយ ម.ស.ម.ក តាំងពីឆ្នាំ ២០២២ នោះទេ)

[45] ម៉ិច ដារា និង អេនឌ្រូ ហាហ្វនើ « ទាហានវាយដំលើអ្នកភូមិក្នុងតំបន់ព្រៃមានទំនាស់នៅខេត្តកំពង់ស្ពឺ ក្រុមអង្គការសិទ្ធិមនុស្សបានលើកឡើង» (វីអូឌី ២៣ កុម្ភៈ ២០២២ លីកាដូ «ហ្លាសញូវ សកម្មជនសហគមន៍ដីធ្លីរងការវាយដំដោយទាហានកងពលតូចលេខ៧០នៅខេត្តកំពង់ស្ពឺ»។ (២៣ កុម្ភៈ ឆ្នាំ២០២២) មេង គ្រុយពន្លក «ទានហ៊ានត្រូវបានចោទថាបានបាញ់កាំភ្លើងព្រមានដាក់ព្រះសង្ឃដែលថែរក្សាព្រៃឈើ» (វីអូឌី ១៤ មេសា ២០២២)

[46] សឿង និមល «ការបិទផ្លូវរារាំងការដាក់ញត្តិរបស់អ្នកភូមិនៅខេត្តព្រះវិហារទាក់ទងក្នុងករណីទំនាស់ដីធ្លីដែលអូសបន្លាយពេលជាច្រើនឆ្នាំកន្លងមក «សារព័ត៌មានខេមបូចា ១៩ មីនា ២០២២) សុន មីនា «ការបណ្តេញពលរដ្ឋចំនួន៣០០គ្រួសារពីដីរដ្ឋចាត់ថាស្របច្បាប់»

**ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២២ - ខេត្តរតនៈគិរី:** ក្រុមហ៊ុនចម្ការកៅស៊ូ ៧មករាផារី បានចាប់ផ្ដើមឈូសឆាយដីស្រែដែលប្រជាពលរដ្ឋជនជាតិដើមភាគតិចចារ៉ាយចំនួន ៩ គ្រួសារ កំពុងធ្វើកសិកម្មក្នុងឃុំញ៉ាង។ ក្រុមហ៊ុនបានឈូសឆាយដើមឈើ ដំណាំ និងបានបិទផ្លូវរារាំងការចូលទៅកាន់ដីនោះដោយពុំមានការជូនដំណឹងជាមុន។ អ្នកភូមិម្នាក់បាននិយាយថាគ្រួសារទាំងនោះបានអាស្រ័យផលលើដីក្នុងតំបន់នេះអស់រយៈពេលប្រមាណបីឆ្នាំមកហើយ ប៉ុន្តែលោកមេឃុំញ៉ាង បានចង្អុលប្រាប់ថាដីស្រែរបស់ពួកគាត់ស្ថិតក្នុងដីរបស់ក្រុមហ៊ុន។[47] មានការលើកឡើងថានៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ ប្រជាពលរដ្ឋរងសម្ពាធឱ្យលក់ដីក្នុងតម្លៃទាបជាងមួយភាគបួននៃតម្លៃទីផ្សារ និងបានប្រាប់ថាក្រុមហ៊ុននឹងដកហូតយកដីទោះបីជាពួកគាត់មិនយល់ព្រមក៏ដោយ។ យោងតាមមន្ត្រីមូលដ្ឋានថ្នាក់ភូមិបានលើកឡើងថាក្រុមហ៊ុន៧មករាផារី បានឈូសឆាយដីរបស់អ្នកភូមិយ៉ាងតិច ៦នាក់ដោយពុំមានចុះកិច្ចសន្យាណាមួយឡើយនៅចន្លោះខែធ្នូ ឆ្នាំ២០២២ និងខែឧសភា ឆ្នាំ២០២៣។ មានការរាយការណ៍ថាអ្នកភូមិទាំងនោះប្រឈមនឹងការគំរាមកំហែង និងការធ្វើទុក្ខបុកម្នេញពីកម្មករ ប្រដាប់ដោយអាវុធរបស់ក្រុមហ៊ុន៧មករាផារី នោះទៀតផង។[48]

**ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២២ - ខេត្តកណ្ដាល:** អាជ្ញាធបានចាប់ផ្ដើមឈូសឆាយដីស្រែជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋប្រមាណ៤០គ្រួសារមកពីភូមិចំនួនបី ក្នុងឃុំស្វាយរមៀត ស្រុកខ្សាច់កណ្ដាលដោយពុំមានការជូនដំណឹងជាមុនដើម្បីអនុញ្ញាតឱ្យក្រសួងធនធានទឹកសាងសង់ប្រឡាយបង្ហូរទឹកកខ្វក់។ គ្រួសារពលរដ្ឋទាំងនោះពុំទទួលបានសំណងឡើយ ទោះបីជាពលរដ្ឋជាច្រើនបានលើកឡើងថាពួកគាត់ខ្ចីបំណុលយកមកទិញដីនោះ។[49]

**ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ - ខេត្តព្រះវិហារ:** ប្រជាពលរដ្ឋប្រមាណ៤០នាក់ក្នុងឃុំភ្នំត្បែង២ និងឃុំស្រយង់ ស្រុកគូលែន បានតវ៉ាបន្ទាប់ពីអាជ្ញាធរខេត្តបានលើកឡើងថាអាជ្ញាធរនឹងឈូសឆាយផ្ទះ និងដីស្រែរបស់ពលរដ្ឋទាំងនោះ ស្ថិតលើដីដែលបានផ្ដល់ទៅឱ្យក្រុមហ៊ុនកសិ-ឧស្សាហកម្មសិលាជាម៉ិច ខូអិលធីឌី ក្នុងខែមីនា ឆ្នាំ២០១១។ ក្នុងខែមីនា ឆ្នាំ២០២២ អាជ្ញាធរខេត្តបានបំផ្លិចបំផ្លាញផ្ទះសម្បែងចំនួន៦០ខ្នង និងឈូសឆាយដីដំណាំប្រមាណ៤៥០ហិកតាដោយពុំមានការជូនដំណឹង ដោយបង្ខំឱ្យប្រជាពលរដ្ឋដែលរងផលប៉ះពាល់ជាច្រើនគ្រួសារប្ដូរទៅរស់នៅក្រោមតង់កៅស៊ូ។ មិនត្រឹមតែពុំផ្ដល់សំណងប៉ុណ្ណោះទេ អាជ្ញាធរព្រមទាំងគំរាមចាប់ខ្លួនសមាជិកសហគមន៍ប្រសិនបើពួកគេហ៊ានតវ៉ា ឬថតរូបភាព។[50]

---

(ខ្មែរថាមស៍ ៣០ មីនា ២០២២) ឃុត សុគុណ ខ្លឿង គីម ហួយ « អាជ្ញាធរខេត្តព្រះវិហារបានហាមប្រជាពលរដ្ឋមិនឱ្យចូលទៅកាន់ដីមានទំនាស់» [ភាសាខ្មែរ] (វីអូឌី ២៤ មីនា ២០២២)

[47] រី រួន «ពលរដ្ឋជនជាតិដើមភាគតិចចារ៉ាយជាច្រើនគ្រួសារលើកឡើងថាដីស្រែ និងចម្ការកៅស៊ូរងការបំផ្លិចបំផ្លាញ» (វីអូឌី ២៣ មិថុនា ២០២២)

[48] ដែក ប្រុក អ៊ឹង ស៊ី «ការគំរាម ការបំផ្លិចបំផ្លាញ និងការបង្ខិតបង្ខំឱ្យលក់: ក្រុមហ៊ុនចម្ការកៅស៊ូបំផ្លិចបំផ្លាញដីស្រែជនជាតិដើមភាគតិចចារ៉ាយ» (សារព័ត៌មានខេមបូចា ២៣ ឧសភា ២០២៣)

[49] ឃុត សុគន្ធ មេង គ្រុយពន្លក «រដ្ឋាភិបាលឈូសឆាយដីរបស់ពលរដ្ឋខេត្តកណ្ដាលដើម្បីធ្វើប្រឡាយបង្ហូរទឹក» (វីអូឌី ០៥ កក្កដា ២០២២)

[50] ឃុត សុគន្ធ « ពលរដ្ឋខេត្តព្រះវិហារចំនួន១៣១ គ្រួសារបារម្ភពីការបណ្ដេញចិត្តបន្ទាប់ផលដំណាំត្រូវបំផ្លិចបំផ្លាញ» (វីអូឌី ១៥ កក្កដា ២០២២)

**ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៣ - ខេត្តព្រះស៊ីហនុ ៖** តាមសេចក្តីរាយការណ៍ អាជ្ញាធរបានរុះរើខ្ទមប្រមាណ ២០០ខ្នង នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ហើយបានគំរាមចាប់ខ្លួនអ្នកដែលស្នាក់នៅនិងតវ៉ា។ មន្ត្រីខេត្តបាននិយាយថា ខ្ទមនេះត្រូវបានសាងសង់នៅលើដីឯកជន ហើយបានកត់សម្គាល់ថាអាជ្ញាធរបានស្នើសុំម្ចាស់ខ្ទមទាំងនោះចាកចេញពីតំបន់នេះកាលពីឆ្នាំ ២០២១។ ពួកគេបានបដិសេធថាមិនបានបំផ្លាញខ្ទម ឬគំរាមចាប់ខ្លួនម្ចាស់ខ្ទមឡើយ តែប្រជាពលរដ្ឋទាំងនោះបានស្ម័គ្រចិត្តប្រគល់ដីឱ្យក្រុមហ៊ុនវិញ ហើយចាកចេញពីទីតាំងនោះ។ ប្រជាពលរដ្ឋបាននិយាយថា ពួកគេមកពីខេត្តផ្សេងៗក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ពួកគេទទួលស្គាល់ថារស់នៅលើដីរដ្ឋពិតមែនហើយ ប៉ុន្តែត្រូវទទួលបានការបែងចែកដីមួយកន្លែងឱ្យរស់នៅផង។[51]

**ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៣ - ខេត្តមណ្ឌលគិរីៈ** មានការលើកឡើងថាមានក្រុមឈ្មួញដែលមានឥទ្ធិពលស្លៀកពាក់ឯកសណ្ឋានទាហាន និងប្រដាប់ដោយកាំភ្លើងច្រើនដើមបានទន្ទ្រានយកដីព្រៃសហគមន៍ជនជាតិដើមភាគតិចបួន ក្នុងស្រុកកោះញែក។ មានការរាយការណ៍ថាក្រុមឈ្មួញទាំងនេះបានទន្ទ្រានយកដីធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ឬលក់ដីព្រៃ ឬតំបន់អភិរក្សរបស់សហគមន៍ជាច្រើនរយហិកតា ដោយបានអះអាងថាពួកគេមានប្លង់ដីដែលផ្តល់សិទ្ធិឱ្យពួកគេកាន់កាប់លើដីដែលជាកេរដំណែលដូនតារបស់សហគមន៍។ ពួកគេព្រមទាំងបានបាញ់កាំភ្លើងបីគ្រាប់ដាក់សមាជិកសហគមន៍ដែលដើរល្បាតព្រៃ ដើម្បីទប់ស្កាត់ការកាប់ឈើទៀតផង។ សហគមន៍មូលដ្ឋានបានរាយការណ៍ករណីនោះទៅកាន់អាជ្ញាធរខេត្ត ប៉ុន្តែបញ្ហានោះពុំទាន់ត្រូវបានដោះស្រាយទេ។[52]

## ៣. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ការបណ្តេញចេញដោយបង្ខំជា**ការរារាំងទាំងស្រុងដល់ការទទួលបានសិទ្ធិមនុស្ស** និងបាននឹងកំពុងកើតឡើងគួរឱ្យព្រួយបារម្ភខ្លាំងនៅប្រទេសកម្ពុជា ចាប់តាំងពីការដកចេញការរឹតបន្តឹងអំឡុងពេលជំងឺកូវីដ-១៩ មក។ គឺជាការចាំបាច់ណាស់ ដែលរាជរដ្ឋាភិបាលត្រូវដោះស្រាយបញ្ហានានាដូចបានលើកឡើងខាងលើដើម្បីការពារសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានដីធ្លី និងលំនៅឋានសមរម្យ។

**ជាចុងក្រោយ ម.ស.ម.ក សូមផ្តល់អនុសាសន៍ជូនដល់រដ្ឋាភិបាល ដូចខាងក្រោម៖**

១. **បញ្ឈប់ជាបន្ទាន់រាល់ការបណ្តេញចេញដែលកំពុងដំណើរការ** រហូតទាល់តែការចរចាលើវិធានការផ្តល់សំណង និងការផ្លាស់ប្តូរទីតាំងថ្មី **ទទួលបានការយល់ព្រមពីសហគមន៍ដែលរងផលប៉ះពាល់**

---

51 ស៊ិន សារ៉ាត «ពលរដ្ឋខេត្តព្រះសីហនុរងការបណ្តេញចេញក្រោយពីមនុស្សបួននាក់រងការចោទប្រកាន់ពីបទទន្ទ្រានយកដីឯកជន» (សារព័ត៌មានខេមបូចា ២៩ ខែសីហា ២០២២)។

52 ជាតិ ចំណា «សហគមន៍ជនជាតិដើមនៅមណ្ឌលគិរីថា ក្រុមឈ្មួញមានឯកសណ្ឋានជាទាហាន លួចកាប់ទន្ទ្រានដីព្រៃសហគមន៍ជច្រើនហិកតា» (វិទ្យុអាស៊ីសេរី ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៣)

២. **ផ្តួចផ្តើមឱ្យមានការពិនិត្យដោយតម្លាភាពជាបន្ទាន់**លើករណីនៃការបណ្តេញចេញដោយបង្ខំទាំងអស់ដែលបានកើតឡើងចាប់តាំងពីមានការរីករាលដាលនៃជំងឺកូវីដ-១៩ និងចាត់វិធានការចាំបាច់ក្នុង**ការផ្តល់ដំណោះស្រាយយ៉ាងមានប្រសិទ្ធភាពលើករណីរំលោភពានសិទ្ធិមនុស្ស ឬការផ្តល់សំណងមិនយុត្តិធម៌** ដែលបានកំណត់ក្នុងដំណើរការនេះ

៣. ផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ច គម្រោងអភិវឌ្ឍន៍ ព្រមទាំងតំបន់អភិរក្សបន្ថែមទៀត រហូតទាល់តែ**ព្រំដីជាកេរដំណែលរបស់សហគមន៍ជនជាតិដើមភាគតិចទទួលការវាស់វែងច្បាស់លាស់** និងមានការយល់ព្រមពីសហគមន៍ជនជាតិដើមភាគតិចនៅមូលដ្ឋាន ព្រមទាំងបែងចែកថវិកាជាតិ និងធនធានមនុស្សដែលចាំបាច់ដើម្បី**ពន្លឿនដំណើរការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីធ្លីសមូហភាព** ឆ្លើយតបគោលបំណងក្នុងការចេញប័ណ្ណកម្មសិទ្ធិដីធ្លីសមូហភាពជូនសហគមន៍ជនជាតិដើមភាគតិចឱ្យបាន ១០សហគមន៍ ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០២៥ តទៅ ដោយអនុលោមតាមការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល និង

៤. ធានាថាការបណ្តេញចេញនាពេលអនាគត **ត្រូវតែអនុលោមតាមច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធ** ពោលគឺ (១) គ្រួសារដែលត្រូវបណ្តេញចេញត្រូវទទួលបាន**សំណងសមរម្យ**ផ្អែកតាមតម្លៃទីផ្សារលើដីដែលពួកគេកំពុងកាន់កាប់ ឬធ្វើកសិដ្ឋាន ហើយទីតាំងលំនៅឋានថ្មីត្រូវស្ថិតនៅក្នុងតំបន់ដែលផ្តល់ភាពងាយស្រួលក្នុងការទទួលបានសេវាមូលដ្ឋាន និងឱកាសប្រកបរបរចិញ្ចឹមជីវិត (២) ការបណ្តេញចេញអាចធ្វើទៅបានតែក្នុង**ជម្រើសចុងក្រោយបង្អស់**ប៉ុណ្ណោះ និង (៣) ការបណ្តេញចេញមិនត្រូវធ្វើឡើងដោយប្រើក**ម្លាំងច្រើនហួសហេតុ ឬពុំសមាមាត្រនោះឡើយ**។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក **វណ្ណ សុផាត** អ្នកសម្របសម្រួលគម្រោងធុរកិច្ច និងសិទ្ធិមនុស្ស នៃ ម.ស.ម.ក តាមរយៈលេខទូរស័ព្ទ +៨៥៥ (0) ១២ ៩៤១ ២០៦ ឬ អ៊ីម៉ែល ៖ vann.sophath@cchrcambodia.org៕